ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ១០.កយ.សសរ/២១

**សេចក្តីសម្រេច**

**ស្តីពី**

**ការបន្តទទួលស្គាល់មន្ត្រីជំនាញ**

**ក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះនៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញសេចក្តីសម្រេចលេខ ១៣៣ កយ.សសរ/១៩ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងយុត្តិធម៌ ស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន
- យោងតាមការចាំបាច់

**សម្រេច**

**ប្រការ ១.-**

ត្រូវបានទទួលស្គាល់ជាអ្នកជំនាញក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀនដល់មន្ត្រីដែលកំពុងបម្រើការងារនៅមន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) ចំនួន០៤រូប ដែលមានសមាសភាពដូចខាងក្រោម៖

១. លោកជំទាវ វិស្វករគីមី **ឈឹម សុខបុណ្យរិទ្ធ** អគ្គលេខាធិការរង និងជាប្រធានមន្ទីរពិសោធន៍គ្រឿងញៀន

២. លោក វេជ្ជបណ្ឌិត **ជុន ហុងតាន** អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀន

Scanned with CamScanner

៣. លោក ឱសថការីឧត្តម ង៉ែត មោនីនោ — អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀន

៤. លោក វិស្វករគីមី យឹម វណ្ណៈ — ប្រធានការិយាល័យបច្ចេកទេស

៥. លោក វេជ្ជបណ្ឌិត លួត សុភា — ប្រធានការិយាល័យវិភាគវត្ថុជីវសាស្ត្រ

**ប្រការ ២.-**

ការបន្តទទួលស្គាល់នេះមានសុពលភាពរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ហើយអាចបន្តជាថ្មីតាមការស្នើសុំ។ ការស្នើសុំបន្តជាថ្មីត្រូវធ្វើយ៉ាងយឺតបំផុតរយៈពេល០១ខែ មុនអស់សុពលភាពនៃសេចក្តីសម្រេចនេះ។ ការបន្តការទទួលនេះអាចដកហូតវិញ ក្នុងករណីសាមីខ្លួនមិនអាចបំពេញលក្ខខណ្ឌសមត្ថភាពផ្នែកជំនាញ សម្ភារៈបច្ចេកទេសការងារ អព្យាក្រឹត្យភាព និងសីលធម៌ ដោយអនុលោមតាមច្បាប់ បទបញ្ញត្តិ និងគោលការណ៍ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

សាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សាមីខ្លួនដើម្បីអនុវត្ត
- ដូចប្រការ៣
  ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner